អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន

## អ.វ.ត.ក. និង ICRC ចុះអនុស្សរណៈយោគយល់គ្នា សម្រាប់ការរៀបចំ ការប្រកួតប្រជែងតុលាការនិម្មិតផ្នែកច្បាប់មនុស្សធម៌អន្តរជាតិ

ភ្នំពេញ ប្រទេសកម្ពុជា - អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MoU) ជាមួយគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម (ICRC) សម្រាប់ការរៀបចំការប្រកួតប្រជែងតុលាការនិម្មិតផ្នែកច្បាប់មនុស្សធម៌អន្តរជាតិនៅកម្ពុជា។ ការរៀបចំព្រឹត្តិការណ៍នេះមានគោលបំណងលើកកម្ពស់ចំណេះដឹងផ្នែកច្បាប់មនុស្សធម៌អន្តរជាតិ ក្នុងចំណោមនិស្សិត អ្នកសិក្សា និងអ្នកពាក់ព័ន្ធដទៃទៀត។

**ឯកឧត្តម ក្រាញ់ តូនី** ប្រធានរដ្ឋបាលស្តីទីនៃ អ.វ.ត.ក. មានប្រសាសន៍ថា៖ «វាជាកិត្តិយសដ៏ឧត្តុងឧត្តមក្នុងការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ជាមួយគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម។ យើងជឿជាក់ថា កិច្ចសហប្រតិបត្តិការនេះ នឹងជួយបង្កើនការរៀនសូត្រអំពីច្បាប់មនុស្សធម៌អន្តរជាតិ ជាផ្នែកសំខាន់នៃយុត្តិសាស្ត្រដែល អ.វ.ត.ក. បានចូលរួមចំណែកយ៉ាងសំខាន់តាមរយៈការស៊ើបអង្កេត និងការជំនុំជម្រះផ្សេងៗ។ ដើម្បីសម្រេចបាននូវគោលបំណងនៃអនុស្សរណៈនេះ អ.វ.ត.ក. នឹងរៀបចំកម្មវិធីប្រកួតប្រជែងតុលាការនិម្មិតផ្នែកច្បាប់មនុស្សធម៌អន្តរជាតិប្រចាំឆ្នាំ ចែករំលែកព័ត៌មានដល់បណ្តាញអ្នកច្បាប់ដែលខ្លួនមាន និងផ្សព្វផ្សាយព័ត៌មាននិងការយល់ដឹង អំពីការប្រកួតប្រជែងតុលាការនិម្មិតផ្នែកច្បាប់មនុស្សធម៌អន្តរជាតិ ក្នុងដំណាក់កាលមុខងារសេសសល់របស់ អ.វ.ត.ក.»។

**លោក Barnabe Reaud** អនុប្រធានអ្នកសម្របសម្រួលផ្នែកការពារនៃ ICRC មានប្រសាសន៍ថា៖ «ICRC សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អ.វ.ត.ក. សម្រាប់ការគាំទ្រជាបន្តបន្ទាប់របស់ខ្លួនក្នុងការទទួលរៀបចំការប្រកួតប្រជែងតុលាការនិម្មិតផ្នែកច្បាប់មនុស្សធម៌អន្តរជាតិ។ តុលាការនិមិត្តនេះ ជាឱកាសដ៏ល្អសម្រាប់និស្សិតច្បាប់ក្នុងការពង្រឹងកម្មវិធីសិក្សា និងចំណេះដឹងរបស់ខ្លួនអំពីច្បាប់មនុស្សធម៌អន្តរជាតិ និងសាខាពាក់ព័ន្ធនៃច្បាប់អន្តរជាតិ។ ក្រុមអ្នកច្បាប់របស់យើងនឹងបន្តគាំទ្រដល់ការអនុវត្តការលើកកម្ពស់ការប្រកួតប្រជែងរបស់តុលាការនិម្មិតផ្នែកច្បាប់មនុស្សធម៌អន្តរជាតិនេះ។ យើងជឿជាក់យ៉ាងមុតមាំថា ការប្រកួតប្រជែងនៅឆ្នាំនេះ នឹងផ្តល់នូវបទពិសោធន៍ពិសេសមួយដល់និស្សិតច្បាប់ តាមរយៈការបង្ហាញអំណះអំណាងផ្លូវច្បាប់របស់ខ្លួននៅចំពោះមុខគណៈវិនិច្ឆ័យនៅ អ.វ.ត.ក.»។

អនុលោមតាមអនុស្សរណៈយោគយល់គ្នានេះ ICRC នឹងបន្តផ្តល់សម្ភារៈច្បាប់ និងផ្តល់ព័ត៌មានទំនាក់ទំនងលម្អិតរបស់ដៃគូសិក្សា និងអ្នកពាក់ព័ន្ធនានា ចំណែកឯ អ.វ.ត.ក. ទទួលខុសត្រូវក្នុងការរៀបចំការប្រកួត រួមទាំងការរៀបចំការប្រកួតប្រជែង

ថ្នាក់ជាតិផងដែរ។ អ.វ.ត.ក. និង ICRC នឹងបន្តគាំទ្រក្រុមឈ្នះ ដើម្បីចូលរួមក្នុងការប្រកួតប្រជែងផ្នែកច្បាប់មនុស្សធម៌អន្តរជាតិក្នុងតំបន់ ឬកម្រិតសកលដែលមានស្រាប់ ដូចជាតុលាការនិម្មិតផ្នែកច្បាប់មនុស្សធម៌អន្តរជាតិនៅហុងកុង។

###

**កំណត់ចំណាំចំពោះបណ្ណាធិការព័ត៌មាន៖**

- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) គឺជាស្ថាប័នតុលាការក្នុងស្រុកមួយ ដែលត្រូវបានបង្កើតឡើងស្របតាមច្បាប់ប្រទេសកម្ពុជា។ អ.វ.ត.ក. មានយុត្តាធិការក្នុងការជំនុំជម្រះក្តីមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរ នៃក្រមព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ បន្ទាប់ពីបញ្ចប់ដំណើរការកាត់ក្តីរបស់ខ្លួន អ.វ.ត.ក. បានចាប់ផ្តើមនៅខែមករា ឆ្នាំ ២០២៣ ដើម្បីអនុវត្តលើមុខងារដែលនៅសេសសល់សម្រាប់រយៈពេលបីឆ្នាំដំបូង ស្របតាមកិច្ចព្រមព្រៀងបន្ថែមរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ។

- ការងាររបស់គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម (ICRC) គឺផ្អែកលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ពិធីសារបន្ថែមនៃអនុសញ្ញា លក្ខន្តិកៈរបស់ខ្លួន - និងលក្ខន្តិកៈនៃកាកបាទក្រហមអន្តរជាតិ និងចលនាអឌ្ឍចន្ទក្រហម - និងសេចក្តីសម្រេចរបស់សន្និសីទអន្តរជាតិនៃកាកបាទក្រហម និងអឌ្ឍចន្ទក្រហម។ ICRC គឺជាអង្គការមិនលំអៀង អព្យាក្រឹត និងឯករាជ្យ ដែលមានបេសកកម្មមនុស្សធម៌ពិសេសក្នុងការការពារអាយុជីវិត និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះដោយជម្លោះប្រដាប់អាវុធ និងស្ថានភាពនៃអំពើហិង្សាផ្សេងទៀត និងការផ្តល់ជំនួយដល់ពួកគេ។ ICRC បានធ្វើការនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាង៤០ឆ្នាំ មកហើយ ដើម្បីធ្វើសកម្មភាពមនុស្សធម៌របស់ខ្លួន និងដើម្បីលើកកម្ពស់ច្បាប់មនុស្សធម៌អន្តរជាតិ រួមទាំងក្នុងចំណោមមជ្ឈដ្ឋានសិក្សាផងដែរ។ មធ្យោបាយមួយក្នុងការលើកកម្ពស់សាខានៃច្បាប់អន្តរជាតិនេះ គឺការចាប់ដៃគូជាមួយសាកលវិទ្យាល័យ និងអ្នកពាក់ព័ន្ធផ្សេងទៀតដើម្បីរៀបចំព្រឹត្តិការណ៍នានាដូចជា ការប្រកួតប្រជែងតុលាការនិម្មិតជាដើម។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**

លោក **គុណ ចិន្តា**
មន្ត្រីទទួលបន្ទុកផ្នែកព័ត៌មាន ផ្នែកកិច្ចការសាធារណៈ
លេខទូរស័ព្ទទំនាក់ទំនង៖ +៨៥៥ (០)១២ ៣៣៦ ០៩៧
អ៊ីម៉ែល៖ kun.chenda@eccc.gov.kh